**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៩៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**មាត្រា១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១ ៥០០ (មួយពាន់ប្រាំរយ)ហិកតា ដែលមានទីតាំងស្ថិតនៅស្រុកពេជ្រាដា ស្រុកអូររាំង និងស្រុកកោះញែក ខេត្តមណ្ឌលគិរី របស់ក្រុមហ៊ុនដាក់ឡាក់ មណ្ឌលគិរី អភិវឌ្ឍន៍ កៅស៊ូ (DAK LAK MONDOLKIRI APHIVATH CAOUT CHOUC CO.Ltd) និងផែនទីប្លង់ទីតាំងដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច និងមានប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុចំនួន ១១ប័ណ្ណ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

**មាត្រា២.-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីស្របតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៩ រោច ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផែនទីបង្ហាញក្បាលដីចុះបញ្ជីដីរដ្ឋជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ច ( ក្រុមហ៊ុនជាក់ឡាក់ )
មណ្ឌលគិរី ស្រុកពេជ្រាដា ឃុំប៊ូស្រា លេខកូដ:១១០៤០៤




| ល.រ | ដីដែលត្រូវចុះបញ្ជី | |
|---|---|---|
| | លេខក្បាលដី | ក្រឡាផ្ទៃ( គិតជា ម² ) |
| 1 | 98 | 2931214.371 |
| 2 | 229 | 60339.31194 |
| 3 | 230 | 604265.2789 |
| 4 | 231 | 1026673.897 |
| 5 | 235 | 3960181.93 |
| 6 | 237 | 1836418.816 |
| 7 | 240 | 2751948.021 |
| 8 | 451 | 44134.18245 |
| 9 | 672 | 1027040.349 |
| 10 | 673 | 25121.50013 |
| 11 | 676 | 713369.9403 |
| Total | | 14980707.6 |
| ដីឃ្លៀលចេញ | | |
| 12 | A | 43112.25733 |
| 13 | B | 60962.4349 |
| 14 | C | 70443.75972 |
| 15 | D | 19881.29883 |
| total | | 194399.7508 |
| ដីព្រៃតំណម | | |
| 16 | E | 110428.6971 |
| 17 | F | 52406.52859 |
| 18 | G | 119738.7285 |
| total | | 172145.2571 |
| ដីមានប័ណ្ណកម្មសិទ្ធិ | | |
| 19 | H | 86738.09296 |
| 20 | I | 24357.69362 |
| 21 | J | 27072.3687 |
| 22 | K | 382591.8103 |
| 23 | L | 1006970.078 |
| total | | 1527730.044 |

| បានឃើញ និងឯកភាព | បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | |
|---|---|---|---|
| មណ្ឌលគិរី. ថ្ងៃទី...ខែ...ឆ្នាំ២០១៨ | មណ្ឌលគិរី. ថ្ងៃទី...ខែ...ឆ្នាំ២០១៨ | មណ្ឌលគិរី. ថ្ងៃទី...ខែ...ឆ្នាំ២០១៨ | មណ្ឌលគិរី. ថ្ងៃទី...ខែ...ឆ្នាំ២០១៨ |
| អភិបាលនៃគណៈអភិបាលខេត្ត | ប្រធានមន្ទីរ ដ.ន.ស.ស ខេត្តមណ្ឌលគិរី | ប្រធានការិយាល័យ ដ.ន.ស.ស ស្រុកពេជ្រាដា | ប្រធានក្រុមវាស់វែង |
| ស្វាយ សំអ៊ាង | ម៉ៅ ចំរើន | | |